ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder
feel the warmth

ក្រសួងទេសចរណ៍

លេខ ០៧១ ប្រក

ថ្ងៃព្រហស្បតិ៍ ១៤កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ២០២០

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ សម្រាប់អាជីវកម្មសេវាកម្មស្នាក់នៅទេសចរណ៍

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពី ការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងទេសចរណ៍

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះ មានគោលបំណងដាក់ឱ្យអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ដល់អាជីវកម្មសេវាកម្មស្នាក់នៅទេសចរណ៍ ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ និងលើកកម្ពស់សុវត្ថិភាពទេសចរណ៍ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅកំណត់អំពីវិធានសុវត្ថិភាពទេសចរណ៍ដល់អាជីវកម្មស្នាក់នៅទេសចរណ៍។

**ប្រការ ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះអាជីវកម្មស្នាក់នៅទេសចរណ៍ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៤.-**

លក្ខខណ្ឌវាយតម្លៃការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ សម្រាប់អាជីវកម្មសេវាកម្មស្នាក់នៅទេសចរណ៍ ក្នុងដំណាក់កាលការរីករាលដាលនៃជំងឺឆ្លងកូវីដ១៩ ត្រូវបានកំណត់ជាឧបសម្ព័ន្ធទី១នៃប្រកាសនេះ។

**ប្រការ ៥.-**

អាជីវកម្មស្នាក់នៅទេសចរណ៍ដែលបំពេញបានលក្ខខណ្ឌកំណត់ក្នុងឧបសម្ព័ន្ធទី១នៃប្រកាសនេះនឹង ទទួលបានឡាបិលទទួលស្គាល់អាជីវកម្មសេវាកម្មស្នាក់នៅទេសចរណ៍ ដែលមានសុវត្ថិភាពប្រឆាំងនឹងកូវីដ១៩ ដែលមានគំរូកំណត់ក្នុងឧបសម្ព័ន្ធទី២នៃប្រកាសនេះ។

**ប្រការ ៦.-**

វិធានសុវត្ថិភាពទេសចរណ៍នេះ ត្រូវបានដាក់ឱ្យអនុវត្តជាកាតព្វកិច្ច និងជាលក្ខខណ្ឌបន្ថែមក្នុងការ ស្នើសុំថ្មី ឬបន្តអាជ្ញាបណ្ណទេសចរណ៍។

គ្រប់អាជីវកម្មទាំងអស់ដែលមិនបានអនុវត្ត ឬអនុវត្តមិនបានត្រឹមត្រូវតាមវិធានសុវត្ថិភាពទេសចរណ៍នេះ នឹងក្លាយជាកម្មវត្ថុនៃការព្យួរអាជ្ញាបណ្ណជាបន្ទាន់ ស្របតាមមាត្រា៨៤ កថាខណ្ឌទី២ នៃច្បាប់ស្ដីពីទេសចរណ៍។

**ប្រការ ៧.-**

វិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មសេវាកម្មស្នាក់នៅទេសចរណ៍នេះ ត្រូវបានដាក់ឱ្យអនុវត្ត ក្នុងដំណាក់កាលទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ ហើយអាចនឹងបន្តក្នុងដំណាក់កាលបន្តទៀតតាម ការចាំបាច់។

**ប្រការ ៨.-**

រាល់បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៩.-**

នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ អគ្គនាយកអភិវឌ្ឍន៍ទេសចរណ៍ និងសហប្រតិបត្តិការអន្តរជាតិ អគ្គាធិការ គ្រប់ប្រធានអង្គភាពក្រោមឱវាទក្រសួងទេសចរណ៍ ប្រធានមន្ទីរ ទេសចរណ៍រាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ។

រដ្ឋមន្ត្រី

ថោង ខុន

**កន្លែងទទួល៖**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ១៩
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- មន្ទីរទេសចរណ៍រាជធានី ខេត្ត
- សហព័ន្ធទេសចរណ៍កម្ពុជា
- សមាគមសណ្ឋាគារកម្ពុជា
- ដូចប្រការ៩
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

ឧបសម្ព័ន្ធ២

នៃប្រកាសលេខ ០៨១ ប្រក. ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ២០២០

ស្តីពី

# វិធានសុវត្ថិភាពសម្រាប់អាជីវកម្មសេវាកម្មស្នាក់នៅទេសចរណ៍

ឡាបិលទទួលស្គាល់អាជីវកម្មសេវាកម្មស្នាក់នៅទេសចរណ៍
ដែលអនុវត្តស្របតាមវិធានសុវត្ថិភាពទេសចរណ៍

## វិធានសុវត្ថិភាពទេសចរណ៍

TOURISM SAFETY MEASURES

# ឧបសម្ព័ន្ធទី១នៃប្រកាសលេខ០៤៤ទសក. ចុះថ្ងៃទី០៤......ខែមិថុនា.........ឆ្នាំ២០២០
# ស្តីពី
# វិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មសេវាកម្មស្នាក់នៅទេសចរណ៍

## គោលការណ៍ណែនាំស្តីពីវិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មសេវាកម្មស្នាក់នៅទេសចរណ៍
## (ក្នុងដំណាក់កាលចូលរួមវិធានការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩)

*****

**"វិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មសេវាកម្មស្នាក់នៅទេសចរណ៍"** ជាបណ្តុំនៃលក្ខខណ្ឌតម្រូវសរុបចំនួន 0៩ ចែកចេញជា ២0 កម្មវត្ថុនៃការវាយតម្លៃ ស្មើនឹង ៧២ ចំនុចត្រូវត្រួតពិនិត្យ (ក្នុងនោះរួមមាន ៣២ ការអនុវត្តតម្រូវចាំបាច់ និង ៤0 ការអនុវត្តជាជម្រើស)។

វិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មសេវាកម្មស្នាក់នៅទេសចរណ៍ មាន ៣ផ្នែក គឺៈ

- **ផ្នែកទី១** ស្តីពី វិធានសុវត្ថិភាពចំពោះភ្ញៀវ រួមមាន 0២លក្ខខណ្ឌតម្រូវ 0៥កម្មវត្ថុនៃការវាយតម្លៃ និង ២0ចំនុចត្រូវត្រួតពិនិត្យ(**ចែកជា 0៦ការអនុវត្តតម្រូវចាំបាច់** និង **១៤ ការអនុវត្តជាជម្រើស**)។
- **ផ្នែកទី២** ស្តីពី វិធានសុវត្ថិភាពចំពោះបុគ្គលិក រួមមាន 0៣លក្ខខណ្ឌតម្រូវ 0៨កម្មវត្ថុនៃការវាយតម្លៃ និង ២៩ចំនុចត្រូវត្រួតពិនិត្យ(**ចែកជា ១៧ការអនុវត្តតម្រូវចាំបាច់** និង **១២ការអនុវត្តជាជម្រើស**)។
- **ផ្នែកទី៣** ស្តីពី វិធានសុវត្ថិភាពចំពោះដៃគូសហប្រតិបត្តិការ និងការគ្រប់គ្រងអាជីវកម្ម រួមមាន 0៤លក្ខខណ្ឌតម្រូវ 0៧កម្មវត្ថុនៃការវាយតម្លៃ និង ២៣ចំនុចត្រូវត្រួតពិនិត្យ(**ចែកជា 0៩ការអនុវត្តតម្រូវចាំបាច់** និង**១៤ការអនុវត្តជាជម្រើស**)

ដើម្បីទទួលបានឡាបិលទទួលស្គាល់អាជីវកម្មសេវាកម្មស្នាក់នៅទេសចរណ៍ដែលអនុវត្តត្រឹមត្រូវតាម **"វិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មសេវាកម្មស្នាក់នៅទេសចរណ៍"** អាជីវកម្មត្រូវបំពេញនូវគ្រប់ ***ចំនុចការអនុវត្តតម្រូវចាំបាច់*** ទាំង ៣២ចំនុច។

### ១. វិធានសុវត្ថិភាពចំពោះភ្ញៀវ

វិធានទី១នេះ សំដៅដល់ការជូនដំណឹង និងផ្តល់ការណែនាំអំពីការអនុវត្តដល់ភ្ញៀវទេសចរដើម្បីចូលរួមបង្ការហានិភ័យដែលអាចកើតមានឡើង។ វិធានការនេះ សំដៅផងដែរដល់ការសម្អាតនិងសម្លាប់មេរោគជាប់ជាប្រចាំនៅតាមកន្លែងចាំបាច់មួយចំនួនដែលយើងគិតថា ជាកន្លែងដែលមានមនុស្សចេញចូលច្រើន ជួបជុំ និងអាចប៉ះពាល់ការរស់រួមគ្នា។

វិធានទី១នេះ មាន <u>០២</u>លក្ខខណ្ឌតម្រូវ <u>០៥</u>កម្មវត្ថុនៃការវាយតម្លៃ និង <u>២០</u>ចំនុចត្រូវត្រួតពិនិត្យ(**ចែកជា ០៦ការអនុវត្តតម្រូវចាំបាច់ និង ១៤ការអនុវត្តជាជម្រើស**)

- លក្ខខណ្ឌតម្រូវទី១(លេខរៀង ១.១) ស្តីពីការផ្សព្វផ្សាយព័ត៌មានដល់ភ្ញៀវ មានកម្មវត្ថុនៃការវាយតម្លៃចំនួន **<u>០២កម្មវត្ថុ</u>** និងមានចំនុចត្រូវត្រួតពិនិត្យសរុបចំនួន **<u>០៦ចំនុច</u> (ការអនុវត្តតម្រូវចាំបាច់ចំនួន០២ និងការអនុវត្តជាជម្រើសចំនួន០៤)**
- លក្ខខណ្ឌតម្រូវទី២(លេខរៀង ១.២) ស្តីពីការណែនាំចំពោះអាកប្បកិរិយារបស់ភ្ញៀវ មានកម្មវត្ថុនៃការវាយតម្លៃចំនួន **<u>០៣កម្មវត្ថុ</u>** និងមានចំនុចត្រូវត្រួតពិនិត្យសរុបចំនួន **<u>១៤ចំនុច</u> (ការអនុវត្តតម្រូវចាំបាច់ចំនួន០៤ និងការអនុវត្តជាជម្រើសចំនួន១០)**។

| ល.រ | លក្ខខណ្ឌតម្រូវ | កម្មវត្ថុនៃការវាយតម្លៃ | ការពន្យល់អំពីការអនុវត្ត | ការពិនិត្យ |
|---|---|---|---|---|
| ១.១ | ការផ្សព្វផ្សាយព័ត៌មានដល់ភ្ញៀវ | ឯកសារផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងការបង្ការវីរុសកូវីដ១៩ ដល់ភ្ញៀវ | ព័ត៌មានផ្សព្វផ្សាយជា ការក្រើនរំលឹកឱ្យលាងដៃ ការក្រើនរំលឹកឱ្យពាក់ម៉ាស់ និង ការរក្សាគម្លាតសុវត្ថិភាពយ៉ាងតិច១,៥ម៉ែត្ររវាងគ្នា | **(ការអនុវត្តតម្រូវចាំបាច់)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | ព័ត៌មានផ្សព្វផ្សាយជា របៀបលាងដៃ របៀបប្រើប្រាស់ម៉ាស់ឱ្យបានត្រឹមត្រូវ ប្រភពស្វែងរកព័ត៌មានបន្ថែមដោយខ្លួនឯង (ហ្វេសប៊ុកក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឬនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងដែលមានគេហទំព័រផ្លូវការ www.cdcmoh.gov.kh និងលេខ**ទូរស័ព្ទទាន់ហេតុការណ៍** (Hotline) **១១៥**) | **(ការអនុវត្តជាជម្រើស)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | ព័ត៌មានផ្សព្វផ្សាយជា ការសម្គាល់លក្ខណៈរោគសញ្ញាដែលត្រូវប្រុងប្រយ័ត្ន យល់ដឹងពីវិធីសាស្រ្តអនុវត្តប្រសិនបើសង្កេតឃើញមាននរណាម្នាក់មានរោគសញ្ញាសង្ស័យ | **(ការអនុវត្តជាជម្រើស)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | ព័ត៌មានផ្សព្វផ្សាយជា គំរូនៃការអនុវត្តងាយៗដើម្បីកាត់បន្ថយការចម្លង ដូចជា ការឱ្យប្រើកែងដៃជំនួសពេលរុញទ្វារ ការទុកគម្លាតសុវត្ថិភាពរវាងគ្នា ជាដើម | **(ការអនុវត្តជាជម្រើស)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | ឯកសារទាំងនោះត្រូវបានបិទផ្សាយ | នៅមុខអាជីវកម្ម(ច្រកចូល) និងនៅក្នុងបន្ទប់ស្នាក់ | **(ការអនុវត្តតម្រូវចាំបាច់)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |

| | | | | |
|---|---|---|---|---|
| | | | នៅមុខច្រកចូលបន្ទប់ទឹក និងនៅក្នុងបរិវេណអាជីវកម្ម ពិសេសនៅតាមកន្លែងដែលមានផ្តល់សេវាកម្ម ឬដាក់ឱ្យប្រើប្រាស់រួម | **(ការអនុវត្តជាជម្រើស)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| ១.២ | **ការណែនាំចំពោះអតិថិជន/ភ្ញៀវ (អ្វីដែលត្រូវធ្វើ និងអ្វីដែលមិនត្រូវធ្វើ)** | ការណែនាំនៅពេលភ្ញៀវចូលទៅក្នុងបរិវេណអាជីវកម្ម | វាស់កម្តៅនៅច្រកចេញចូល លាងដៃនឹងសាប៊ូ ឬទឹកអាល់កុលលាងដៃ ឬជែល និងត្រូវបាញ់ទឹកអាល់កុលសម្លាប់មេរោគនៅលើ ស្បែកជើងមុនចូលក្នុងបរិវេណអាជីវកម្ម និងរក្សាគម្លាតសុវត្ថិភាព ១,៥ម៉ែត្រនៅរាល់ពេលតម្រង់ជួររង់ចាំ។ ត្រូវមានសារជូនដំណឹងអំពីការអនុវត្តទាំងនេះ | **(ការអនុវត្តតម្រូវចាំបាច់)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | ស្នើសុំឱ្យភ្ញៀវចុះឈ្មោះប្រើប្រាស់សេវាកម្ម ដោយមានបញ្ជាក់អត្តសញ្ញាណរបស់ភ្ញៀវឱ្យបានច្បាស់លាស់ | **(ការអនុវត្តតម្រូវចាំបាច់)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | មានបុគ្គលិកប្រចាំការផ្តល់ជំនួយដល់ភ្ញៀវ | **(ការអនុវត្តជាជម្រើស)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | ការណែនាំនៅពេលភ្ញៀវចូលទៅដល់ក្នុងបរិវេណអាជីវកម្ម | តម្រូវឱ្យធ្វើដំណើរតាមទិសចរាចរ (ឯកទិស) ដែលបានកំណត់ទុកនៅរាល់ពេលឈររង់ចាំ បម្លាស់ទីទៅមកក្នុងអាជីវកម្ម ចូលបន្ទប់ទឹក-ល-។ ត្រូវមានសារជូនដំណឹងអំពីការអនុវត្តនេះ ឬគំនូសបំព្រួញសម្គាល់ជាក់ស្តែង | **(ការអនុវត្តតម្រូវចាំបាច់)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | មានបុគ្គលិកប្រចាំការផ្តល់ជំនួយដល់ភ្ញៀវ | **(ការអនុវត្តជាជម្រើស)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | ការណែនាំនៅពេលភ្ញៀវស្ថិតនៅកន្លែងផ្តល់សេវាកម្ម ឬ | រក្សាគម្លាតសុវត្ថិភាព(យ៉ាងតិច១,៥ម៉ែត្រ) និងមានគំនូសសម្គាល់បែងចែកសុវត្ថិភាព។ តម្រូវឱ្យរៀបចំកន្លែងអង្គុយស្របតាមការណែនាំរបស់ក្រសួងសុខាភិ | **(ការអនុវត្តតម្រូវចាំបាច់)**<br>□ មានគ្រប់គ្រាន់ |

| | | | | |
|---|---|---|---|---|
| | | កន្លែងប្រើប្រាស់រួមណាមួយ | បាល | □ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | មានបុគ្គលិកប្រចាំការផ្តល់ជំនួយដល់ភ្ញៀវ | **(ការអនុវត្តជាជម្រើស)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | ក្នុងករណីដែលភ្ញៀវចូលទៅប្រើប្រាស់សេវាកម្មណាមួយ សំណូមពរឱ្យភ្ញៀវប្រើប្រាស់សេវាកម្មនៅនឹងកន្លែងយ៉ាងយូរត្រឹម៦០នាទីក្នុងមួយលើក ដើម្បីកាត់បន្ថយអត្រាចម្លង និងផ្តល់ឱកាសឱ្យភ្ញៀវបន្ទាប់អាចចូលប្រើប្រាស់សេវាកម្មបន្ត(ពីព្រោះលទ្ធភាពទទួលរបស់អាជីវកម្មត្រូវកាត់បន្ថយ) | **(ការអនុវត្តជាជម្រើស)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | សំណូមពរឱ្យភ្ញៀវកក់ទុកជាមុនរាល់ការស្នើសុំប្រើប្រាស់សេវាកម្មផ្សេងៗ (ដើម្បីងាយស្រួលគ្រប់គ្រងចំនួនភ្ញៀវ) | **(ការអនុវត្តជាជម្រើស)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | សំណូមពរឱ្យភ្ញៀវកក់បន្ទប់ទុកជាមុន (ដើម្បីងាយស្រួលគ្រប់គ្រងចំនួនភ្ញៀវ និងព័ត៌មានរបស់ភ្ញៀវ) | **(ការអនុវត្តជាជម្រើស)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | សំណូមពរឱ្យភ្ញៀវប្រើប្រាស់សម្ភារៈផ្ទាល់ខ្លួន ដូចជា កន្សែង ក្រាសសិតសក់ ឡាមកោរពុកមាត់ ។ល។ | **(ការអនុវត្តជាជម្រើស)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | សំណូមពរឱ្យភ្ញៀវប្រើសញ្ញារាល់ពេលស្នើសុំជំនួយពីបុគ្គលិកបម្រើសេវាកម្ម ជៀសវាងការប្រើសម្លេងខ្លាំងៗស្នើសុំជំនួយពីបុគ្គលិកបម្រើសេវាកម្ម | **(ការអនុវត្តជាជម្រើស)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | សំណូមពរឱ្យភ្ញៀវបំពេញទម្រង់បញ្ចេញមតិចំពោះសេវាកម្ម ដោយមានបញ្ជាក់ឈ្មោះពេញ និងអាសយដ្ឋាន | **(ការអនុវត្តជាជម្រើស)**<br>□ មានគ្រប់គ្រាន់ |

| | | | | |
|---|---|---|---|---|
| | | | | ☐ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | សំណូមពរឱ្យភ្ញៀវប្រើប្រាស់សេវាកម្មទូទាត់តាមប្រព័ន្ធអេឡិចត្រូនិច<br>(E-payment) | **(ការអនុវត្តជាជម្រើស)**<br>☐ មានគ្រប់គ្រាន់<br>☐ មានមិនគ្រប់គ្រាន់ ឬមិនមាន |

**២. វិធានសុវត្ថិភាពចំពោះបុគ្គលិក**

វិធានទី២នេះ: សំដៅដល់ការគ្រប់គ្រងបុគ្គលិកទាំងអស់ដែលបម្រើការនៅក្នុងបរិវេណអាជីវកម្ម។ ត្រូវរាប់បញ្ចូលទាំងបុគ្គលិកពេញសិទ្ធិ បុគ្គលិកបម្រើការក្រៅម៉ោង និងបុគ្គលិកហាត់ការ។

វិធានទី២នេះ: មាន <u>០៣</u>លក្ខខណ្ឌតម្រូវ <u>០៤</u>កម្មវត្ថុនៃការវាយតម្លៃ និង <u>២៩</u>ចំនុចត្រូវត្រួតពិនិត្យ**(ចែកជា ១៧ការអនុវត្តតម្រូវចាំបាច់ និង១២ការអនុវត្តជាជម្រើស)**

- លក្ខខណ្ឌតម្រូវទី១(លេខរៀង ២.១) ស្តីពីការផ្សព្វផ្សាយព័ត៌មានដល់បុគ្គលិក មានកម្មវត្ថុនៃការវាយតម្លៃចំនួន **<u>០២កម្មវត្ថុ</u>** និងមានចំនុចត្រូវត្រួតពិនិត្យសរុបចំនួន **<u>០៥ចំនុច</u>** **(ការអនុវត្តតម្រូវចាំបាច់ចំនួន០៤ និងការអនុវត្តជាជម្រើសចំនួន០១)**
- លក្ខខណ្ឌតម្រូវទី២(លេខរៀង ២.២) ស្តីពីការបណ្តុះបណ្តាល មានកម្មវត្ថុនៃការវាយតម្លៃចំនួន **<u>០២កម្មវត្ថុ</u>** និងមានចំនុចត្រូវត្រួតពិនិត្យសរុបចំនួន **<u>០៦ចំនុច</u>** **(ការអនុវត្តតម្រូវចាំបាច់ចំនួន០២ និងការអនុវត្តជាជម្រើសចំនួន០៤)**
- លក្ខខណ្ឌតម្រូវទី៣(លេខរៀង ២.៣) ស្តីពីការណែនាំចំពោះអកប្បកិរិយារបស់បុគ្គលិក មានកម្មវត្ថុនៃការវាយតម្លៃចំនួន **<u>០៤កម្មវត្ថុ</u>** និងមានចំនុចត្រូវត្រួតពិនិត្យសរុបចំនួន **<u>១៨ចំនុច</u>** **(ការអនុវត្តតម្រូវចាំបាច់ចំនួន១១ និងការអនុវត្តជាជម្រើសចំនួន៧)**។

| ល.រ | លក្ខខណ្ឌតម្រូវ | កម្មវត្ថុនៃការវាយតម្លៃ | ការពន្យល់អំពីការអនុវត្ត | ការពិនិត្យ |
|---|---|---|---|---|
| ២.១ | **ការផ្សព្វផ្សាយព័ត៌មានដល់បុគ្គលិក** | ឯកសារផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងការបង្ការវីរុសកូវីដ១៩ ដល់បុគ្គលិក | ព័ត៌មានផ្សព្វផ្សាយជា ការក្រើនរំលឹកឱ្យលាងដៃ ការក្រើនរំលឹកឱ្យពាក់ម៉ាស់ និង ការរក្សាគម្លាតសុវត្ថិភាពយ៉ាងតិច១,៥ម៉ែត្ររវាងគ្នា | **(ការអនុវត្តតម្រូវចាំបាច់)**<br>☐ មានគ្រប់គ្រាន់<br>☐ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | ព័ត៌មានផ្សព្វផ្សាយជា របៀបលាងដៃ របៀបប្រើប្រាស់ម៉ាស់ឱ្យបានត្រឹមត្រូវ ប្រភពស្វែងរកព័ត៌មានបន្ថែមដោយខ្លួនឯង (ហ្វេសប៊ុកក្រសួងសុខាភិបាលនៃ | **(ការអនុវត្តតម្រូវចាំបាច់)**<br>☐ មានគ្រប់គ្រាន់ |

| | | | | |
|---|---|---|---|---|
| | | | ព្រះរាជាណាចក្រកម្ពុជា ឬនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងដែលមានគេហទំព័រផ្លូវការ www.cdcmoh.gov.kh និងលេខ**ទូរស័ព្ទទាន់ហេតុការណ៍** (Hotline) **១១៥**) | □ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | ព័ត៌មានផ្សព្វផ្សាយជា ការសម្គាល់លក្ខណៈរោគសញ្ញាដែលត្រូវប្រុងប្រយ័ត្ន យល់ដឹងពីវិធីសាស្ត្រអនុវត្តប្រសិនបើសង្កេតឃើញមាននរណាម្នាក់មានរោគសញ្ញាសង្ស័យ | **(ការអនុវត្តតម្រូវចាំបាច់)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | ព័ត៌មានផ្សព្វផ្សាយជា គំរូនៃការអនុវត្តងាយៗដើម្បីកាត់បន្ថយការចម្លង ដូចជា ការឱ្យប្រើកែងដៃជំនួសពេលរុញទ្វារ ការទុកគម្លាតសុវត្ថិភាពរវាងគ្នា ជាដើម | **(ការអនុវត្តជាជម្រើស)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | ឯកសារទាំងនោះត្រូវបានបិទផ្សាយ | នៅក្នុងបរិវេណបន្ទប់បុគ្គលិក បន្ទប់ទឹកបុគ្គលិក និងនៅកន្លែងប្រតិបត្តិការការងារ | **(ការអនុវត្តតម្រូវចាំបាច់)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| ២.២ | ការបណ្តុះបណ្តាលបុគ្គលិក | ឯកសារបណ្តុះបណ្តាលពាក់ព័ន្ធនឹងការបង្ការវីរុសកូវីដ១៩ ដល់បុគ្គលិក | បណ្តុះបណ្តាលដល់បុគ្គលិកគ្រប់រូបនូវរាល់ការណែនាំរបស់ក្រសួងសុខាភិបាលពាក់ព័ន្ធនឹងវិធានអនាម័យ និងការបង្ការវីរុសកូវីដ១៩ | **(ការអនុវត្តតម្រូវចាំបាច់)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | បណ្តុះបណ្តាលដល់បុគ្គលិកគ្រប់រូបអំពីជំនាញក្នុងប្រតិបត្តិការការងារ | **(ការអនុវត្តជាជម្រើស)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | រៀបចំជាបញ្ជីឈ្មោះបុគ្គលិកដោយមានបញ្ជាក់អ្នកដែលបានទទួលការបណ្តុះបណ្តាលពាក់ព័ន្ធនឹងវិធានអនាម័យនិងការបង្ការវីរុសកូវីដ១៩ និងជំនាញក្នុងប្រតិបត្តិការការងារ | **(ការអនុវត្តជាជម្រើស)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | មានអ្នកគ្រប់គ្រងទទួលខុសត្រូវចំពោះការងារបណ្តុះបណ្តាល | **(ការអនុវត្តជាជម្រើស)**<br>□ មានគ្រប់គ្រាន់ |

| | | | | |
|---|---|---|---|---|
| | | | | □ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | បុគ្គលិកគ្រប់ផ្នែកទទួលបានការបណ្តុះបណ្តាល | បុគ្គលិកជួរមុខ បុគ្គលិកគេហកិច្ច អ្នកជញ្ជូនឥវ៉ាន់ បុគ្គលិកអនាម័យ សន្តិសុខ អ្នកដែលទទួលខុសត្រូវតាមដានការអនុវត្ត និងបុគ្គលិកបម្រើការតាមផ្នែកផ្សេងទៀតប្រសិនបើមាន (ដូចជា គ្រូបង្វឹកនៅកន្លែងហាត់ប្រាណ ឆ្មាំប្រចាំការនៅអាងហែលទឹក បុគ្គលិកបម្រើការនៅភោជនីយដ្ឋាន ជាដើម) | **(ការអនុវត្តតម្រូវចាំបាច់)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | បុគ្គលិកគ្រប់ផ្នែកទទួលបានការបណ្តុះបណ្តាលពាក់ព័ន្ធវិធានអនាម័យនិងការបង្ការវីរុសកូវីដ១៩ និងជំនាញក្នុងប្រតិបត្តិការការងារ | **(ការអនុវត្តជាជម្រើស)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| ២.៣ | **ការណែនាំចំពោះអតិថិជនរបស់បុគ្គលិក (អ្វីដែលត្រូវធ្វើ និងអ្វីដែលមិនត្រូវធ្វើ)** | ការណែនាំនៅពេលបុគ្គលិកចូល និងត្រឡប់ចូលទៅក្នុងបរិវេណអាជីវកម្ម | វាស់កម្តៅនៅច្រកចេញចូល លាងដៃនឹងសាប៊ូឬទឹកអាល់កុលលាងដៃឬជែល និងត្រូវបាញ់ទឹកអាល់កុលសម្លាប់មេរោគនៅលើស្បែកជើង មុនចូលក្នុងបរិវេណអាជីវកម្ម និងរក្សាគម្លាតសុវត្ថិភាព ១,៥ម៉ែត្រនៅរាល់ពេលតម្រង់ជួររង់ចាំ។ ត្រូវមានសារជូនដំណឹងអំពីការអនុវត្តទាំងនេះ | **(ការអនុវត្តតម្រូវចាំបាច់)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | មានអ្នកប្រចាំការផ្តល់ជំនួយនិងឃ្លាំមើលការអនុវត្តរបស់បុគ្គលិក | **(ការអនុវត្តជាជម្រើស)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | បុគ្គលិកត្រូវចុះវត្តមានប្រចាំថ្ងៃ និងចុះឈ្មោះក្នុងសៀវភៅចេញចូលដោយមានបញ្ជាក់ម៉ោង និងគោលបំណង | **(ការអនុវត្តជាជម្រើស)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | ការណែនាំនៅពេលបុគ្គលិកចូលទៅដល់ក្នុងបរិវេណអាជីវកម្ម និងនៅពេលកំពុង | តម្រូវឱ្យធ្វើដំណើរតាមទិសចរាចរ (ឯកទិស) ដែលបានកំណត់ទុកនៅរាល់ពេលឈររង់ចាំ បម្លាស់ទីទៅមកក្នុងអាជីវកម្ម ចូលបន្ទប់ទឹក ល។ និងប្រកាន់ខ្ជាប់នូវគម្លាតសុវត្ថិភាព(យ៉ាងតិច១,៥ម៉ែត្រ)។ ត្រូវមានសារជូនដំណឹងអំពីការ | **(ការអនុវត្តតម្រូវចាំបាច់)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |

| | | | | |
|---|---|---|---|---|
| | | បំពេញការងារ | អនុវត្តនេះ ឬគំនូសបំព្រួញសម្គាល់ជាក់ស្ដែង | |
| | | | កម្រិតការបម្លាស់ទីចេញចូលរបស់បុគ្គលិកពីរង្វង់តំបន់ការងារទទួលខុសត្រូវ និងកម្រិតរាល់ការប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយបុគ្គលិកផ្សេងទៀត នៅអំឡុងម៉ោងការងារ | **(ការអនុវត្តជាជម្រើស)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | រាល់វត្ថុនិងសម្ភារៈប្រើប្រាស់រួម (ដូចជា បន្ទប់ទឹកបុគ្គលិក ទូរដាក់សម្ភារៈ-ល-) ត្រូវកម្រិតការប្រើប្រាស់ឱ្យបាននៅត្រឹមកម្រិតទាបបំផុតក្នុងដំណាក់កាលនេះ។ ក្នុងករណីជៀសវាងពុំបាន ត្រូវណែនាំឱ្យបុគ្គលិកសម្អាតវត្ថុនិងសម្ភារៈទាំងនោះរៀងរាល់ពេលប្រើប្រាស់រួច | **(ការអនុវត្តជាជម្រើស)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | មានអ្នកប្រចាំការផ្ដល់ជំនួយនិងឃ្លាំមើលការអនុវត្តរបស់បុគ្គលិក | **(ការអនុវត្តជាជម្រើស)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | ការណែនាំបន្ថែមចំពោះបុគ្គលិកអនាម័យ | លាងសម្អាតរាល់វត្ថុនិងសម្ភារប្រើប្រាស់រួម(ទ្វារចេញចូល ដៃទ្វារ ជណ្ដើរយន្ត កៅអីរង់ចាំ ទូរស័ព្ទសាធារណៈ បន្ទប់ទឹកសាធារណៈ បង្កាន់ដៃ-ល-) ឱ្យបានញឹកញាប់(រៀងរាល់១ម៉ោងម្ដង) និងឱ្យបានត្រឹមត្រូវ(តាមការណែនាំរបស់ក្រសួងសុខាភិបាល) | **(ការអនុវត្តតម្រូវចាំបាច់)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | លាងសម្អាតបន្ទប់ស្នាក់នៅរាល់ពេលភ្ញៀវចាកចេញមួយលើកៗ (រាប់ទាំងការចាកចេញបញ្ចប់ការស្នាក់នៅ និងការចាកចេញក្នុងគោលបំណងផ្សេងទៀត) | **(ការអនុវត្តតម្រូវចាំបាច់)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | ផ្លាស់ប្ដូរកម្រាលពូក ស្រោមខ្នើយ ភួយ កន្សែងជូតខ្លួន ជូតដៃ ជូតមុខ ក្រដាសអនាម័យ និងសម្ភារៈផ្សេងទៀតសម្រាប់ប្រើប្រាស់ក្នុងបន្ទប់ស្នាក់ រៀងរាល់ពេលភ្ញៀវចាកចេញមួយលើកៗ ទោះបីមិនមានការស្នើសុំឱ្យផ្លាស់ប្ដូរក៏ដោយ និងត្រូវធ្វើដោយប្រុងប្រយ័ត្នជៀសវាងការប៉ះពាល់កាកសំណល់ | **(ការអនុវត្តតម្រូវចាំបាច់)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |

| | | | | |
|---|---|---|---|---|
| | | | ក្រដាសជូតមាត់ ឬសម្ភារៈដែលប្រើរួចជាដើម | |
| | | | ត្រូវពាក់ស្រោមដៃសុវត្ថិភាពជាប់ជានិច្ច និងលាងសម្អាតទាំងដៃមានស្រោមដៃនេះជាមួយសាប៊ូឬទឹក អាល់កុលឬជែលឱ្យបានញឹកញាប់។ ត្រូវពាក់ម៉ាស ឯកសណ្ឋានឱ្យបានត្រឹមត្រូវ និងរក្សាគម្លាតសុវត្ថិភាពរាល់ពេលបំពេញការងារ | (ការអនុវត្តតម្រូវចាំបាច់)<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | រាល់ការសម្អាតត្រូវមានកាលវិភាគនិងវេណសម្អាតត្រឹមត្រូវ | (ការអនុវត្តតម្រូវចាំបាច់)<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | មានអ្នកប្រចាំការឃ្លាំមើលការអនុវត្តរបស់បុគ្គលិក | (ការអនុវត្តជាជម្រើស)<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | ការណែនាំបន្ថែមចំពោះបុគ្គលិកជួរមុខ | ត្រូវពាក់ស្រោមដៃសុវត្ថិភាព ពាក់ម៉ាស់ ឯកសណ្ឋានត្រឹមត្រូវ និងរក្សាគម្លាតសុវត្ថិភាពពីភ្ញៀវជាប់ជានិច្ច | (ការអនុវត្តតម្រូវចាំបាច់)<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | ត្រូវសំណូមពរឱ្យភ្ញៀវឈរតម្រង់ជួរឱ្យបានត្រឹមត្រូវនៅពេលចុះឈ្មោះស្នាក់នៅ និងត្រូវតម្រូវឱ្យស្នាក់នៅត្រឹម០២នាក់យ៉ាងច្រើនសម្រាប់០១បន្ទប់ស្នាក់ | (ការអនុវត្តតម្រូវចាំបាច់)<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | ត្រូវសាកសួរ និងបញ្ចូលទិន្នន័យរបស់ភ្ញៀវ ទៅក្នុងប្រព័ន្ធចុះបញ្ជីស្នាក់នៅតាមប្រព័ន្ធអនឡាញរបស់ក្រសួងទេសចរណ៍ដែលមានគេហទំព័រផ្លូវការ<br>www.accommodationregistrar.net | (ការអនុវត្តតម្រូវចាំបាច់)<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | ត្រូវទទួលយកថវិកាទូទាត់ដោយប្រុងប្រយ័ត្ន (ប្រើទ្រនាប់ទ្រ) និងស្នើជម្រើសទូទាត់តាមអេឡិចត្រូនិច | (ការអនុវត្តតម្រូវចាំបាច់)<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |

| | | | | |
|---|---|---|---|---|
| | | | មានអ្នកប្រចាំការឃ្លាំមើលការអនុវត្តរបស់បុគ្គលិក | **(ការអនុវត្តជាជម្រើស)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |

## ៣. វិធានសុវត្ថិភាពចំពោះដៃគូសហប្រតិបត្តិការ និងការគ្រប់គ្រងអាជីវកម្ម

វិធានទី៣នេះ: សំដៅដល់ការកំណត់ទំនាក់ទំនងជាមួយភាគីទី៣ដែលអាចនឹងបង្កជាហានិភ័យ មានដូចជា: អ្នកផ្គត់ផ្គង់ អ្នកដឹកទំនិញ ជាង និងដៃគូផ្សេងទៀតដែលអាចជាក្រុមហ៊ុនទីភ្នាក់ងារទេសចរណ៍ មគ្គុទ្ទេសក៍ទេសចរណ៍ អាជីវកម្មទេសចរណ៍ផ្សេងទៀត។ល។

វិធានទី៣នេះ: មាន <u>០៤</u>លក្ខខណ្ឌតម្រូវ <u>០៧</u>កម្មវត្ថុនៃការវាយតម្លៃ និង <u>២៣</u>ចំនុចត្រួវត្រួតពិនិត្យ(**ចែកជា ០៩ការអនុវត្តតម្រូវចាំបាច់ និង១៤ការអនុវត្តជាជម្រើស)**

- លក្ខខណ្ឌតម្រូវទី១(លេខរៀង ៣.១) ស្ដីពីការផ្សព្វផ្សាយព័ត៌មានដល់ដៃគូសហប្រតិបត្តិការ មានកម្មវត្ថុនៃការវាយតម្លៃចំនួន **<u>០២កម្មវត្ថុ</u>** និងមានចំនុចត្រូវត្រួតពិនិត្យសរុបចំនួន **<u>០៦ចំនុច</u>** (**ការអនុវត្តតម្រូវចាំបាច់ចំនួន០២ និងការអនុវត្តជាជម្រើសចំនួន០៤)**
- លក្ខខណ្ឌតម្រូវទី២(លេខរៀង ៣.២) ស្ដីពីការណែនាំចំពោះអកប្បកិរិយារបស់ដៃគូសហប្រតិបត្តិការ មានកម្មវត្ថុនៃការវាយតម្លៃចំនួន **<u>០២កម្មវត្ថុ</u>** និងមានចំនុចត្រូវត្រួតពិនិត្យសរុបចំនួន **<u>០៦ចំនុច</u>** (**ការអនុវត្តតម្រូវចាំបាច់ចំនួន០២ និងការអនុវត្តជាជម្រើសចំនួន០៤)**
- លក្ខខណ្ឌតម្រូវទី៣(លេខរៀង ៣.៣) ស្ដីពីការគ្រប់គ្រងប្រតិបត្តិការអាជីវកម្ម មានកម្មវត្ថុនៃការវាយតម្លៃចំនួន **<u>០១កម្មវត្ថុ</u>** និងមានចំនុចត្រូវត្រួតពិនិត្យសរុបចំនួន **<u>០២ចំនុច</u>** (**ការអនុវត្តតម្រូវចាំបាច់ចំនួន០១ និងការអនុវត្តជាជម្រើសចំនួន០១)**
- លក្ខខណ្ឌតម្រូវទី៤(លេខរៀង ៣.៤) ស្ដីពីការគ្រប់គ្រងទីតាំងអាជីវកម្ម មានកម្មវត្ថុនៃការវាយតម្លៃចំនួន **<u>០២កម្មវត្ថុ</u>** និងមានចំនុចត្រូវត្រួតពិនិត្យសរុបចំនួន **<u>០៩ចំនុច</u>(ការអនុវត្តតម្រូវចាំបាច់ចំនួន០៤ និងការអនុវត្តជាជម្រើសចំនួន០៥)**។

| ល.រ | លក្ខខណ្ឌតម្រូវ | កម្មវត្ថុនៃការវាយតម្លៃ | ការពន្យល់អំពីការអនុវត្ត | ការពិនិត្យ |
|---|---|---|---|---|
| ៣.១ | ការផ្សព្វផ្សាយព័ត៌មានដល់ដៃគូសហប្រតិបត្តិការ | ឯកសារផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងការបង្ការវីរុសកូវីដ១៩ ដល់ដៃគូសហប្រតិបត្តិការ | ព័ត៌មានផ្សព្វផ្សាយជា ការក្រើនរំលឹកឱ្យលាងដៃ ការក្រើនរំលឹកឱ្យពាក់ម៉ាស់ និង ការរក្សាគម្លាតសុវត្ថិភាពយ៉ាងតិច១,៥ម៉ែត្រវាងគ្នា | **(ការអនុវត្តតម្រូវចាំបាច់)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | ព័ត៌មានផ្សព្វផ្សាយជា របៀបលាងដៃ របៀបប្រើប្រាស់ម៉ាស់ឱ្យបានត្រឹមត្រូវ | **(ការអនុវត្តជាជម្រើស)** |

| | | | | |
|---|---|---|---|---|
| | | | ប្រភពស្វែងរកព័ត៌មានបន្ថែមដោយខ្លួនឯង (ហ្វេសប៊ុកក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឬនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងដែលមានគេហទំព័រផ្លូវការ www.cdcmoh.gov.kh និងលេខ**ទូរស័ព្ទទាន់ហេតុការណ៍**(Hotline) **១១៥**) | □ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | ព័ត៌មានផ្សព្វផ្សាយជា ការសម្គាល់លក្ខណៈរោគសញ្ញាដែលត្រូវប្រុងប្រយ័ត្ន យល់ដឹងពីវិធីសាស្ត្រអនុវត្តប្រសិនបើសង្កេតឃើញមាននរណាម្នាក់មានរោគសញ្ញាសង្ស័យ | **(ការអនុវត្តជាជម្រើស)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | ព័ត៌មានផ្សព្វផ្សាយជា គំរូនៃការអនុវត្តងាយៗដើម្បីកាត់បន្ថយការចម្លង ដូចជា ការឱ្យប្រើកែងដៃជំនួសពេលរុញទ្វារ ការទុកគម្លាតសុវត្ថិភាពរវាងគ្នា ជាដើម | **(ការអនុវត្តជាជម្រើស)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | ឯកសារទាំងនោះត្រូវបានបិទផ្សាយ | នៅតាមច្រកចេញចូលដែលដៃគូសហប្រតិបត្តិការឆ្លងកាត់ | **(ការអនុវត្តតម្រូវចាំបាច់)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | នៅមុខច្រកចូលបន្ទប់ទឹកសាធារណៈ និងនៅក្នុងបរិវេណអាជីវកម្ម | **(ការអនុវត្តជាជម្រើស)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| ៣.២ | **ការណែនាំចំពោះអតិថិជនរបស់ដៃគូសហប្រតិបត្តិការ (អ្វីដែលត្រូវធ្វើ និងអ្វីដែលមិនត្រូវធ្វើ)** | ការណែនាំនៅពេលដៃគូសហប្រតិបត្តិការចូលទៅក្នុងបរិវេណអាជីវកម្ម | វាស់កម្តៅនៅច្រកចេញចូល លាងដៃនឹងសាប៊ូ ឬទឹកអាល់កុលលាងដៃឬជែល និងត្រូវបាញ់ទឹកអាល់កុលសម្លាប់មេរោគនៅលើ ស្បែកជើងមុនចូលក្នុងបរិវេណអាជីវកម្ម និងរក្សាគម្លាតសុវត្ថិភាព ១៥ម៉ែត្រនៅរាល់ពេលតម្រង់ជួររង់ចាំ។ ត្រូវមានសារជូនដំណឹងអំពីការអនុវត្តទាំងនេះ | **(ការអនុវត្តតម្រូវចាំបាច់)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | ត្រូវចុះឈ្មោះក្នុងសៀវភៅចេញចូលដោយមានបញ្ជាក់ម៉ោង និងគោលបំណង | **(ការអនុវត្តជាជម្រើស)**<br>□ មានគ្រប់គ្រាន់ |

| | | | | |
|---|---|---|---|---|
| | | | | □ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | មានបុគ្គលិកប្រចាំការផ្តល់ជំនួយនិងឃ្លាំមើលការអនុវត្ត | **(ការអនុវត្តជាជម្រើស)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | ការណែនាំនៅពេលចូលទៅដល់ក្នុងបរិវេណអាជីវកម្ម និងនៅពេលកំពុងបំពេញការងារ | តម្រូវឱ្យធ្វើដំណើរតាមទិសចរាចរ (ឯកទិស) ដែលបានកំណត់ទុកនៅរាល់ពេលឈររង់ចាំ បម្លាស់ទីទៅមកក្នុងអាជីវកម្ម ចូលបន្ទប់ទឹក-ល- និងប្រកាន់ខ្ជាប់នូវគម្លាតសុវត្ថិភាព(យ៉ាងតិច១,៥ម៉ែត្រ)។ ត្រូវមានសារជូនដំណឹងអំពីការអនុវត្តនេះ ឬគំនូសបំព្រួញសម្គាល់ជាក់ស្តែង | **(ការអនុវត្តតម្រូវចាំបាច់)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | កម្រិតការបម្លាស់ទីចេញចូលត្រឹមវង្វង់តំបន់ការងារទទួលខុសត្រូវ និងកម្រិតរាល់ការប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយអ្នកដទៃនៅអំឡុងម៉ោងការងារ | **(ការអនុវត្តជាជម្រើស)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | មានអ្នកប្រចាំការផ្តល់ជំនួយនិងឃ្លាំមើលការអនុវត្ត | **(ការអនុវត្តជាជម្រើស)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| ៣.៣ | **ការគ្រប់គ្រងប្រតិបត្តិការអាជីវកម្ម** | ឯកសារក្រមប្រតិបត្តិសម្រាប់ការអនុវត្តល្អ<br>ឯកសារណែនាំការអនុវត្ត | គ្រប់ចំនុចនៃការណែនាំខាងលើ មានចងក្រងជាក្រមប្រតិបត្តិសម្រាប់ការអនុវត្តល្អ និងដាក់បិទផ្សាយនៅក្នុងបរិវេណអាជីវកម្ម | **(ការអនុវត្តតម្រូវចាំបាច់)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | គ្រប់ចំនុចនៃការណែនាំខាងលើ មានចងក្រងជាឯកសារណែនាំសម្រាប់ការអនុវត្ត | **(ការអនុវត្តជាជម្រើស)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| ៣.៤ | **ការគ្រប់គ្រងទីតាំងអាជីវកម្ម** | ការបំពាក់សម្ភារៈ | រៀបចំឱ្យមានទឹកអាល់កុល ឬជែលសម្រាប់លាងដៃ ឬសាប៊ូនិងទឹកស្អាត សម្រាប់ភ្ញៀវ បុគ្គលិក និងដៃគូសហប្រតិបត្តិការនៅមុខកន្លែងច្រកចេញចូល | **(ការអនុវត្តតម្រូវចាំបាច់)**<br>□ មានគ្រប់គ្រាន់ |

| | | | | |
|---|---|---|---|---|
| | | | នៅក្នុងអាជីវកម្ម និងនៅតាមកន្លែងដទៃទៀតដែលមានឱកាសប៉ះពាល់វត្ថុរួមគ្នា ដូចជា បន្ទប់ទឹកសាធារណៈ កន្លែងទទួលភ្ញៀវ ជាដើម | □ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | រៀបចំបំពាក់ប្រព័ន្ធកាមេរ៉ាសុវត្ថិភាពនៅក្នុងបរិវេណអាជីវកម្មពិសេសនៅកន្លែងទទួលភ្ញៀវ និងនៅតាមគ្រប់កន្លែងដែលផ្តល់សេវាកម្មរួម ឬប្រើប្រាស់រួម | **(ការអនុវត្តជាជម្រើស)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | រៀបចំបំពាក់សម្ភារៈដំណើរការដោយស្វ័យប្រវត្តិដូចជា ទ្វារបិទបើកស្វ័យប្រវត្តិ បង្គន់បង្ហូរទឹកស្វ័យប្រវត្តិ កន្លែងលាងដៃបង្ហូរទឹកស្វ័យប្រវត្តិ | **(ការអនុវត្តជាជម្រើស)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | ការគ្រប់គ្រង | រៀបចំកៅអីអង្គុយនៅកន្លែងរង់ចាំឱ្យមានគម្លាតពីគ្នាយ៉ាងតិច ១,៥ម៉ែត្រ រវាងភ្ញៀវម្នាក់ទៅភ្ញៀវម្នាក់ទៀតស្របតាមការណែនាំរបស់ក្រសួងសុខាភិបាល | **(ការអនុវត្តតម្រូវចាំបាច់)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | រៀបចំឱ្យមានទិសចរាចរក្នុងបរិវេណហាងសម្រាប់ភ្ញៀវ(ចេញនិងចូលផ្សេងគ្នា) និងរៀបចំគំនូសខណ្ឌដែនរក្សាគម្លាតសុវត្ថិភាពរវាងមនុស្សម្នាក់ទៅម្នាក់ទៀត | **(ការអនុវត្តតម្រូវចាំបាច់)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | កំណត់ចំនួនអ្នកប្រើប្រាស់ជណ្តើរយោង ដើម្បីរក្សាគម្លាតសុវត្ថិភាពស្របតាមការណែនាំរបស់ក្រសួងសុខាភិបាល | **(ការអនុវត្តតម្រូវចាំបាច់)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | បើកបង្អួចក្នុងបរិវេណអាជីវកម្មឱ្យមានខ្យល់ និងពន្លឺថ្ងៃចេញចូលបានល្អ (កាត់បន្ថយឱ្យបានជាអតិបរិមា ឬកុំបើកម៉ាស៊ីនត្រជាក់) | **(ការអនុវត្តជាជម្រើស)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | រៀបចំឱ្យមានប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណរបស់ភ្ញៀវដែលចូលមកប្រើប្រាស់សេវាកម្ម | **(ការអនុវត្តជាជម្រើស)**<br>□ មានគ្រប់គ្រាន់ |

| | | | | |
|---|---|---|---|---|
| | | | | □ មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | | រៀបចំឱ្យមានសញ្ញាជូនដំណឹងផ្សេងៗអំពីអាកប្បកិរិយាងាយៗដែលចូលរួមបង្ការការចម្លង និងត្រូវបិតផ្សាយនៅតាមទីកន្លែងដែលត្រូវប្រើប្រាស់។ ឧទាហរណ៍ សញ្ញាប្រាប់ឱ្យប្រើកែងដៃជំនួសពេលរុញទ្វារ សញ្ញាប្រាប់ឱ្យទុកចន្លោះរវាងគ្នា ជាដើម៕ | **(ការអនុវត្តជាជម្រើស)**<br>□ មានគ្រប់គ្រាន់<br>□ មានមិនគ្រប់គ្រាន់ ឬមិនមាន |

*****